CITY OF LONG BEACH

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
ការិយាល័យផែនការ
411 W. Ocean Boulevard, 2nd Floor, Long Beach, CA 90802
562.570.6194 | longbeach.gov/lbcd

# កម្មវិធីលើកទឹកចិត្ត ក្នុងការកាត់បន្ថយពន្ធអចលនទ្រព្យច្បាប់ Mills Act

## ទិដ្ឋភាពទូទៅ

កម្មវិធីកាត់បន្ថយពន្ធលើអចលនទ្រព្យរបស់ទីក្រុងឡុងប៊ិច ហៅកាត់ថា "ច្បាប់ Mills Act " ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1993 ក្រោមសិទ្ធិអំណាចនៃច្បាប់របស់រដ្ឋ។ កម្មវិធីនេះ គឺជាការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ម្ចាស់អចលនទ្រព្យដែលធ្វើការជួសជុល ស្តារឬកែលម្អឡើងវិញ ឬថែទាំអចលទ្រព្យដែលបានកំណត់ថាជាអចលនទ្រព្យប្រវត្តិសាស្ត្រ ។ អចលនទ្រព្យ ត្រូវតែបានកំណត់ថាជាកន្លែងសំគាល់ប្រវត្តិសាស្ត្ររបស់ទីក្រុងឡុងប៊ិច ឬ រចនាសម្ព័ន្ធដែលរួមចំណែកនៅក្នុងសង្កាត់ប្រវត្តិសាស្ត្រ ដើម្បីទទួលបានកិច្ចសន្យាច្បាប់ Mills Act ។

គោលបំណងនៃកម្មវិធីច្បាប់ Mills Act គឺដើម្បីលើកទឹកចិត្តដល់អចលទ្រព្យ ការការពារ និងការស្តារឡើងវិញនៃអចលនទ្រព្យប្រវត្តិសាស្ត្រ ដែលបានកំណត់ឃើញ។ ម្ចាស់អចលនទ្រព្យដែលចូលរួម ត្រូវចុះកិច្ចសន្យាជាផ្លូវការជាមួយទីក្រុងសម្រាប់ **រយៈពេលយ៉ាងតិច 10 ឆ្នាំ**។ កិច្ចសន្យាថ្មី ត្រូវបានបន្តដោយស្វ័យប្រវត្តិជារៀងរាល់ឆ្នាំសម្រាប់រយៈពេល 10 ឆ្នាំ ហើយត្រូវបានផ្ទេរទៅម្ចាស់ថ្មីនៅពេលអចលនទ្រព្យត្រូវបានលក់។ ម្ចាស់អចលនទ្រព្យយល់ព្រមធ្វើការជួសជុល ថែរក្សា និងការពារអចលទ្រព្យ ដោយអនុលោមតាមស្តង់ដារ និងលក្ខខណ្ឌនៃការអភិរក្សប្រវត្តិសាស្ត្រជាក់លាក់ ដែលមាននៅក្នុងកិច្ចសន្យា។ ការចូលទៅក្នុងកិច្ចសន្យារបស់ច្បាប់ Mills Act អាចបណ្តាលឱ្យមានការវាយតម្លៃឡើងវិញនូវពន្ធលើអចលនទ្រព្យ ដោយអ្នកវាយតម្លៃរបស់ខោនធី ដោយប្រើវិធីសាស្ត្រនៃចំណូល-មូលធននីយកម្ម ដែលអាចបណ្តាលឱ្យមានការកាត់បន្ថយពន្ធអចលនទ្រព្យប្រហែលពី 30 ទៅ 50 ភាគរយ។

## សិទ្ធិក្នុងការទទួលបានកម្មវិធី

ដើម្បីដាក់ពាក្យសុំកិច្ចសន្យារបស់ច្បាប់ Mills Act, អចលនទ្រព្យត្រូវតែស្ថិតនៅក្នុងសង្កាត់ប្រវត្តិសាស្ត្រ ឬជាអគារសម្គាល់ប្រវត្តិសាស្ត្រដែលបានកំណត់ បំពេញតាមតម្លៃអចលនៈទ្រព្យអតិបរមា និងផ្តល់ផែនការស្តារឬកែលម្អឡើងវិញ។ អចលនទ្រព្យ ដែលមិនទាន់ត្រូវបានកំណត់ថាជាកន្លែងសម្គាល់ប្រវត្តិសាស្ត្រ អាចដាក់ពាក្យស្នើសុំអំពីកំណត់នោះ ក្នុងពេលដំណាលគ្នា ដើម្បីយកមកពិចារណាសម្រាប់ការកំណត់កន្លែងសម្គាល់។

## <u>ការរៀបចំ និងការដាក់ពាក្យ</u>

បេក្ខជនដែលមានចំណាប់អារម្មណ៍ ឬអ្នកតំណាងរបស់ពួកគេ ត្រូវតែចូលរួមសិក្ខាសាលាទាំងពីរ ដើម្បីពិចារណា សម្រាប់កម្មវិធីលើកទឹកចិត្តក្នុងការកាត់ពន្ធលើអចលនទ្រព្យ ឆ្នាំ 2024៖

- **សិក្ខាសាលាមុនការដាក់ពាក្យសុំ ដោយផ្ទាល់៖ ថ្ងៃសៅរ៍ ទី 20 ខែមករា ឆ្នាំ 2024 ម៉ោង 10 ព្រឹក រហូតដល់ថ្ងៃត្រង់** ក្នុងមជ្ឈមណ្ឌលសហគមន៍ Cal Rec នៅឯ Ernest McBride Park, 1550 Martin Luther King Jr Ave.
- **សិក្ខាសាលាដាក់ពាក្យសុំ តាមអ៊ីនធឺរណិត៖ ថ្ងៃសៅរ៍ ទី 10 ខែកុម្ភៈ ឆ្នាំ 2024 ម៉ោង 10 ព្រឹក រហូតដល់ថ្ងៃត្រង់ តាមរយៈ** Zoom

បន្ទាប់ពីចូលរួមសិក្ខាសាលាទាំងពីនេះរួច បេក្ខជនដែលមានចំណាប់អារម្មណ៍ ឬអ្នកតំណាងរបស់ពួកគេ ត្រូវបំពេញទម្រង់ពាក្យសុំ និងប្រមូលផ្តុំឯកសារបន្ថែមដែលត្រូវការទាំងអស់។

## <u>កញ្ចប់កម្មវិធីដែលបានបញ្ចប់ពេញលេញ មានដូចខាងក្រោម៖</u>

សម្ភារៈទាំងអស់ គួរតែត្រូវបានបញ្ជូនតាមអេឡិចត្រូនិកដោយគិតថ្លៃ។ ឯកសារនឹងត្រូវបានផ្ទេរតាមរយៈវិធីសាស្ត្រទីក្រុងឡុងប៊ិចដែលមានសុវត្ថិភាព ហើយនៅតាមបញ្ជរ USBs នឹងត្រូវដោះស្រាយតាមករណីនីមួយៗ។

ថ្ងៃផុតកំណត់នៃការដាក់ស្នើនូវកញ្ចប់នៃពាក្យសុំដែលបញ្ចប់ពេញលេញ គឺនៅ **ថ្ងៃសុក្រ ទី 1 ខែមីនា ឆ្នាំ 2024 ម៉ោង 3:00 រសៀល**។

**<u>ទំនាក់ទំនង៖</u>** សម្រាប់ព័ត៌មានបន្ថែម ឬសំណួរទាក់ទងនឹងច្បាប់ Mills Act សូមផ្ញើអ៊ីមែលទៅកាន់ MillsAct@longbeach.gov ឬទូរស័ព្ទទៅ Gina Casillas តាមលេខ 562.570.6879 ឬ Alejandro Plascencia តាមលេខ 562.570.6437 ឬចូលទៅកាន់គេហទំព័រ៖ MillsAct@longbeach.gov ។

ដើម្បីស្នើសុំព័ត៌មាននេះជាទម្រង់ផ្សេង ឬស្នើសុំនូវការសម្របសម្រួល ដែលមានភាពសមហេតុផលណាមួយ, សូមទាក់ទងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ តាម longbeach.gov/lbcd និងទូរស័ព្ទ 562.570.3807។ យើងខ្ញុំត្រូវការពេលយ៉ាងហោចណាស់បីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីលៃលកដោះស្រាយទៅតាមការស្នើសុំនោះ។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំនិងខិតខំដោះស្រាយអោយអស់ពីលទ្ធភាពដើម្បីឆ្លើយតបតាមការស្នើសុំ ដែលបានដាក់ជូនក្នុងរយៈពេលខ្លីជាងនេះ។